# អនុបុព្វិកថា

បណ្ឌិត ឌុម-ណាគ្រី

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង

រៀបរៀង



[illegible]

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

# អនុបុព្វិកថា

បណ្ឌិត ឧម-ណាគ្រី

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង

រៀបរៀង



បណ្ណាគារ [illegible] លេខ ៣០ ផ្លូវ

វិថីប៉ាស្ទ័រ ក្រុងភ្នំពេញ

ព.ស. ២៤៩៧ គ.ស. ១៩៥៤

# អារម្ភកថា

«អនុបុព្វិកថា» គឺជាធម៌សំដែងជាលំដាប់ជាប់ដំណគ្នា តាំងអំពីជាន់ទាប ដរាបដល់ជាន់ខ្ពស់ សំរាប់សំរឹងសំរិតស្រួលចិត្តអ្នកស្តាប់ ឲ្យចាប់ចូលចង់ចំណង់ក្នុងការស្តាប់មិនធុញទ្រាន់ ព្រះភគ-វន្តអរហន្តមុនី កាលគង់ធរមាននៅ ទ្រង់តែងសំដែងថ្លែងរឿយៗ ញយៗ បណ្តាលបណ្តុះបំផុះ បំផុល អប់រំបន្ទំនិស្ស័យសត្វឲ្យជឿស៊ប់ដោយប្រាជ្ញ ហេតុផលយ៉ាងសមរម្យ ឃើញច្បាស់ត្រចះជាក់ថែង សត្វរមែងជ្រះថ្លានឹងធម៌ទេសនាជាច្រើនអនេកពេកអនន្ត អវសាននៃអនុបុព្វិកថា ទ្រង់ទេសនាធម៌អរិយសច្ច បង្ហាញនិស្ស័យសត្វឲ្យយល់បរមត្ថប្រ-យោជន៍ បង្រួបបុព្វជួនចិត្តឲ្យឈូតជិតស្និទ្ធចូលកាន់អារ្យចិត្ត ដរាបដល់បិទកិលេសបេះតណ្ហាបាសាសវៈ ទម្លាក់ធុរៈលោក ឈប់ដេកក្នុងផ្ទះឈប់ត្រាំក្នុងភព ចូលទៅមូលដ៏ត្រជាក់ត្រជុំអភិរម្យចិត្ត ឥតជាតិ ជរា ព្យាធិ មរណៈ ជាឯកៈអគ្គៈបរមសុខ ស្រុកអារ្យៈបុគ្គលវិបុលក្សេមផ្សេមក្សាន្ត គឺ សិវដ្ឋាននិព្វានពិតប្រាកដ ។

ខ្ញុំយល់ថា អនុបុព្វិកថា មានប្រយោជន៍ដល់មិត្តភក្តិបរិស័ទ អ្នកប្រតិបត្តិ អ្នកសិក្សា អ្នកទេសនា អ្នកសវនាទូទៅ ទើបសរសេរអធិប្បាយកំចាយសេចក្តីខ្លីសង្ខេប អ្នកទស្សនាគប់សេពលេបអក្សររបស់សៀវភៅនេះ គង់នឹងបានស្គាល់យល់ហេតុផលដ៏ពិតនៃសុខុម របស់

ពុទ្ធសាសនិកជនមិនខាន ។

កាល ព.ស. ២៤៩៣ - ៩៤ ខ្ញុំបានរៀបរៀងសៀវភៅបែបៈទេសនា គឺ និយកថា ១ សត្តកថា ១ និងបោះពុម្ពផ្សាយ ឃើញថាសហធម្មិកទាំងឡាយ ចូលចិត្តជាវទិញទៅសិក្សា ដោយចំនួនច្រើន ឥឡូវនេះ សៀវភៅ **អនុបុព្វីកថា** ដែលលោកអ្នកកាន់មើលនឹងដៃនេះ គួររាប់ថាជាសៀវភៅទី ៣ របស់ខ្ញុំ សង្ឃឹមថានឹងបានជាទីនិយមនៃក្រុមមិត្តពុទ្ធសាសនិកជន ដូចសៀវភៅនិយកថានិងសត្តកថាមិនខាន ។

ដោយវិរិយភាពរបស់ខ្ញុំនេះ ៖

សូមពុទ្ធសាសន៍រុងរឿងរោចន៍ជានិរន្តរ៍ !<br>
សូមឲ្យជនកម្ពុជៈ ភ្ញាក់គំនិត !<br>
សូមរដ្ឋធម្មនុញ្ញ ជាវីរៈ បិត !<br>
តាមកិរិតប្រជាធិបតេយ្យអើយ !!!

ថ្ងៃទី ១៥ ឧសភា ព.ស. ២៤៩៥

បណ្ឌិត ឡុម - ណាគ្រី

ឃុំស្វាយពោ ស្រុកសង្កែ ខេត្តបាត់ដំបង .

# អនុបុព្វិកថា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ឱកាសនេះ សូមលើកយក "អនុបុព្វិកថា" មកទេសនាពន្យល់ ដល់លោកអ្នក ពុទ្ធិកសប្បុរសទាំងប្រុសស្រី ដើម្បីជាគ្រឿងកើតកំណើត គំនិតបញ្ញា និងការប្រព្រឹត្តដោយសន្តិតសន្ទើបទ្វី ដូចសេចក្តីតទៅនេះ ។

លោកអ្នកបរិស័ទទាំងឡាយ ! មនុស្សយើងដែលបានយកកំ-ណើតកើតមកនៅក្នុងលោកសន្និវាសនេះ រមែងតែងមានសន្តានចិត្តគំនិត អធ្យាស្រ័យផ្សេងៗពីគ្នាជាធម្មតា ។ ព្រោះដូច្នោះ បានជាព្រះពុទ្ធទាំង-ឡាយគ្រប់អង្គ កាលទ្រង់ប្រកាសត្រាស់សំដែងធម៌ដល់ពួកសត្វ ព្រះអង្គ ទ្រង់ប្រមើលមើលនូវបរិស្រ័យនៃសរណសីលបុព្វាទិគុណជាមុន ហើយ ទើបសំដែងធម៌សមស្របតម្រូវឲ្យត្រូវតាមអធ្យាស្រ័យរបស់សត្វនោះៗ ។

សត្វពួកខ្លះ ជាអ្នកជំពាក់ជាប់ចិត្តជិតកន្ទល់ដល់ការងារជាអាជីវកម្ម ក្នុងលោក ទ្រង់ដោតកំសំដែងប្រដៅពន្យល់ ដោយប្រយោជន៍បច្ចុប្បន្ន ទាន់ភ្នែក ដើម្បីឲ្យដឹងពិធីជាទីតាំងខ្លួនឲ្យរួចមាំក្នុងផ្លូវលោក ។ សត្វពួកខ្លះ ជាអ្នកជ្រះថ្លាធ្ងន់ធ្ងរ ក្នុងសីលធម៌ ទ្រង់សំដែងប្រដៅដោយសម្បរាយិកប្រ-យោជន៍ឲ្យតាំងខ្លួនក្នុងសីលធម៌ ដើម្បីតាំងជីវិតអនាគតរបស់ខ្លួនឲ្យមាន ដំណើររៀបរយនិងរីករាយ ឬជាផ្លូវជំនួយដល់ការតាំងខ្លួនក្នុងផ្លូវលោក

ឲ្យបានត្រឹមត្រូវត្រង់ទីងតង់វង់បំភត់ថេរបេរកាលផង ព្រោះមនុស្សដែល តាំងខ្លួននៅក្នុងផ្លូវលោកបាន បើមិនមានសីលធម៌ជួយទប់ទល់គាំទ្រផង ទេ ក៏តាំងនៅមិនខ្ជាប់ខ្ជួនមាំមួនឡើយ ។ សត្វពួកខ្លះជ្រះថ្លាពេញ ចិត្តក្នុងធម៌ ល្អិតល្អន់ជាន់ខ្ពស់ល្មមនឹងសង្គ្រោះដឹកនាំក្នុងរឿងចេញចាក ផាកបោល ពីសេចក្ដីចំពាក់ចំពប់ងប់ងោកក្នុងលោកវិស័យបាន ក៏ទ្រង់ ទូន្មានដោយបរមប្រយោជន៍ គឺប្រយោជន៍ខ្ពស់បំផុតដោយប្រយោជន៍ឲ្យទៅ ព្រះនិព្វាន ។ ការទូន្មានប្រៀនប្រដៅខាងក្រោយ ដើម្បីឲ្យបានលុះ ប្រយោជន៍ដ៏ខ្ពស់នោះ គឺសំដែងឲ្យឃើញច្បាស់នូវអរិយសច្ច ៤ មាន ទុក្ខអរិយសច្ចជាដើម ។*

ដើម្បីញុំាងអ្នកស្ដាប់ឲ្យចាប់ចិត្តឲ្យស្និទ្ធចូលចំណូលចំណុះចុះក្នុងពាក្យ ទូន្មានប្រៀនប្រដៅ ព្រះពុទ្ធជាម្ចាស់ ទ្រង់លើកយកអនុបុព្វីកថា មកទេសនាមុននឹងសំដែងអរិយសច្ច ព្រោះបើលើកយកអរិយសច្ចឡើង សំដែងតែម្ដងទៅ តាមដែលធ្លាប់ដឹងហើយថា សេចក្ដីរបស់អរិយសច្ច គឺ រឿងទុក្ខ នឹងរូបភាពទុក្ខ ;អ្នកស្ដាប់ដែលមិនបានត្រៀមហេតុខាងដើមក្នុង ការពិចារណាឲ្យឃើញថា ពិភពលោកជាទីសោកគ្រោកជាទុក្ខគួរនឿយ ណាយជាមុនទេ ឬបានឮរឿងទុក្ខ ៗ ក្ដៅ ៗ ឬរឿងដែលថាពិភពលោកជា ទីសោកគ្រោកគួររំខាន គួរនឿយណាយ មិនមានអ្វីដែលល្អស្អាត គួរឲ្យ រីករាយសប្បាយសោះ” ដូចនេះ ជាហេតុនាំឲ្យអន់អាក់ មិនសូវស្រគ

ចិត្តគិត ប្រ...ប់ធម៌ប៉ុន្មានឡើយ ។ ហេតុនេះហើយបានជាព្រះពុទ្ធជាម្ចាស់ ទ្រង់លើកយកអនុបុព្វិកថា មកទេសនាជាគ្រឿងលួងលោមបំពួមទឹកចិត្តរបស់សត្វជាមុន ទើបសំដែងអរិយសច្ចជាខាងក្រោយ ។

## អនុបុព្វិកថាគឺអ្វី?

អនុបុព្វិកថា ប្រែថា "ការពោលធម៌ជាលំដាប់លំដោយគ្នា" គឺ មានធម៌ជាលំដាប់តាំងពីជាន់ទាបរៀងរហូតដល់ជាន់ខ្ពស់ ជាលំដាប់ជាប់តាំងពីទី ១ ដល់ទី ៥ ទឹងជាលំដាប់កាំ សំរាប់ឈានទៅរកការសំដែងអរិយសច្ច ។

អនុបុព្វិកថា ការពោលធម៌ជាលំដាប់តាំងពីទី ១ ដល់ទី៥ នោះគឺ:

១- ទាន: ការឲ្យវត្ថុរបស់ខ្លួនដល់អ្នកដទៃ

២- សីល: ការរក្សាកាយវាចាឲ្យរាបសា

៣- សគ្គ: ឋានសួគ៌

៤- កាមាទីនវ: ទោសរបស់កាម

៥- នេក្ខម្មានិសំស: អានិសង្សនៃការបួស

មានសេចក្តីអធិប្បាយ បរិយាយ ដូចតទៅនេះ

១- ទាន: ការឲ្យ "វត្ថុដែលគួរឲ្យ" ដល់ "បុគ្គលដែលគួរឲ្យ"

ជាសេចក្ដីសំដៅរបស់ពាក្យថា "ទាន" ក្នុងទីនេះ ។ "វត្ថុដែលគួរឲ្យ" នោះ គឺរបស់ដែលអ្នកទទួលអាចយកទៅប្រើជាប្រយោជន៍ដល់ខ្លួនបានក្នុងផ្លូវដែលមិនខុស ដូចយ៉ាងសំពត់អាវសាវស្បៃ ទីសំណាក់ជាក់អាស្រ័យ អាហារបរិភោគ ថ្នាំកែរោគជាដើម ។ បើឲ្យថ្នាំកែរោគ ដល់មនុស្សដែលត្រូវការអាហារ ឬឲ្យគ្រឿងសំលៀកបំពាក់ ដល់អ្នកដែលត្រូវការទីសំណាក់ជាក់អាស្រ័យ របស់នោះរមែងមិនជាប្រយោជន៍ ព្រោះខុសសេចក្ដីត្រូវការរបស់អ្នកទទួល ឬបើឲ្យវត្ថុជាកំឡាំងដល់ចោរជាមនុស្សបាបអាក្រក់ វានឹងនាំរបស់ដែលបានទទួលទៅប្រើក្នុងផ្លូវខុស របស់នោះ ទើបមិនជាទានវត្ថុ គឺរបស់ដែលគួរឲ្យឡើយ ។

"បុគ្គលដែលគួរឲ្យនោះ" បែងចែកជាបីប្រភេទ គឺមនុស្សកំសត់ទុគ៌តវិកលវិការ ជាមនុស្សដែលគួរឲ្យដោយអនុគ្រោះ ១ មនុស្សដែលមានឋានៈស្មើ ៗ នឹងយើងគួរឲ្យដោយឋានៈសង្គ្រោះចំពោះគ្នានឹងគ្នា ១ មនុស្សដែលមានឧបការៈលើយើងដូចមាតាបិតាឬមនុស្សដែលមានគុណធម៌ខ្ពស់ ដូចភិក្ខុសាមណេរជាក្រុមសមណៈ គួរឲ្យដោយបូជាគុណ ១ ។

ឲ្យដល់មនុស្សទុគ៌ត ជាការសំដែងសេចក្ដីមេត្តាអាណិតអាសូរ ,
ឲ្យដល់មនុស្សដែលមានឋានៈស្មើនឹងយើង ជាការសំដែងសេចក្ដីមេត្រីរាប់អានអើពើដល់គ្នានឹងគ្នា ជាការចងមិត្តទុកបានយ៉ាងល្អ ,
ឲ្យដល់អ្នកគួរបូជា ដូចមាតាបិតា ជាការសំដែងសេចក្ដី

កតញ្ញូកតវេទី ឬឲ្យផលសមគួរៈ ក៏ជាការសំដែងសេចក្ដីគោរពក្នុងសីលធម៌ ដោយឲ្យកំឡាំងដល់អ្នកប្រព្រឹត្តល្អ លះសិទ្ធិទាំងអស់ក្នុងផ្លូវលោក ចេញបួសប្រព្រឹត្តខ្លួនក្នុងផ្លូវស្ងប់ ហើយខ្លួននាំប្រៀនប្រដៅសត្វលោកឲ្យស្ងប់ផង ។

ម្យ៉ាងទៀត ការឲ្យទានដែលមានផលានិសង្សច្រើននោះ ត្រូវប្រកបដោយអង្គ៣ គឺទានវត្ថុមិនអាក្រក់ជារបស់ដែលខ្លួនបរិភោគប្រើប្រាស់ ទឹងជាធម្មលទ្ធវត្ថុ ធម្មិកវត្ថុ គឺរបស់ដែលបានមកដោយធម៌ កើតឡើងដោយធម៌ ប្រកបដោយធម៌ មិនជារបស់បានមកដោយទុច្ចរិត ឆបោកលួចប្លន់ ឆក់ដណ្ដើម សំឡាប់សំឡេះអ្នកដទៃ ១; អ្នកឲ្យតាំងចិត្តឲ្យពេញចិត្តឲ្យមែន ១ ឲ្យដោយសទ្ធាជាញាណសម្បយុត្ត ឲ្យដោយមានហេតុផល ដល់ព្រមដោយ ចេតនាទាំង ៣ កាល គឺបុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនា មុនឲ្យ កំពុងឲ្យ ឲ្យរួចហើយ ក៏មានចិត្តត្រេកអរជ្រះថ្លា ១ ។

ការឲ្យដោយសទ្ធាជ្រះថ្លា មិនមែនឲ្យដោយសោះតែខាន ឬកញ្ជះកញ្ជាយ ព្រះពុទ្ធជាម្ចាស់ត្រាស់សរសើរថា "សទ្ធាយ ទានំ ទទតោ ឯវំ បុញ្ញំ បវឌ្ឍតិ" "ទាយកឲ្យទានដោយសទ្ធាជ្រះថ្លា បុណ្យរមែងចំរើន."

អ្នកទទួលជាមនុស្សដែលគួរឲ្យយ៉ាងខ្ពស់ គឺជាអ្នកមានគុណធម៌

ជាព្រះទក្ខិណេយ្យបុគ្គល មានព្រះអរិយបុគ្គលជាទីបំផុត ១; ឬឲ្យដល់អ្នកប្រព្រឹត្តសុចរិត ដោយ កាយ វាចា ចិត្ត មានសីលធម៌យ៉ាងទាបក្តី ទានដែលឲ្យដល់ពួកគណៈ មិនរើសមុខបដិគ្គាហកៈ ដូចសង្ឃទានជាដើមក្តី ទាននោះទើបមានផលច្រើនបដិគ្គាហក. អ្នកទទួលនោះ ទាយកអ្នកឲ្យ ត្រូវតែពិនិត្យពិច័យលៃលកមើលជាមុន ព្រោះបដិគ្គាហកៈជាស្រែបុណ្យរបស់ទាយក ទាយកដូចកសិករអ្នកសាបព្រោះបណ្តុះពូជ បើដីស្រែមានជីជាតិល្អមានទឹកបរិបូណ៌ ពូជដែលសាបព្រោះក៏ដុះឡើងល្អដែរយ៉ាងណាមិញ ? បដិគ្គាហកៈក៏យ៉ាងនោះ ត្រូវជាអ្នកបរិបូណ៌ដោយសីលធម៌ បំណងប្រយោជន៍ដល់ពពួកសត្វមានរាគៈ ទោសៈ មោហៈ អស់ហើយ ឬក៏ពុងប្រតិបត្តិដើម្បីលះកាត់កំចាត់ រាគៈ ទោសៈ មោហៈ ហេតុដល់កល្យាណបុថុជ្ជន អ្នកធ្ងន់ក្នុងសីលធម៌ ប្រព្រឹត្តល្អដោយកាយវាចាចិត្ត ទើបចាត់ថាជាស្រែដ៏ល្អបាន ទានដែលបុគ្គលរើសឲ្យដូចនេះរមែងមានផលច្រើន សមដូចពុទ្ធភាសិតថា

វិចេយ្យ ទានំ ទាតព្វំ យត្ថ ទិន្នំ មហប្ផលំ

ទានដែលបុគ្គលឲ្យហើយក្នុងបុញ្ញក្ខេត្តណា រមែងមានផលច្រើន គប្បីពិនិត្យឲ្យក្នុងបុញ្ញក្ខេត្តនោះ ៗ

យេ ទក្ខិណេយ្យា ឥធ ជីលោកេ

តេសុ ទិន្នានិ មហប្ផលានិ
ពីជានិ វុត្តានិ យថា សុខេត្តេ

"ព្រោះទានដែលបុគ្គលឲ្យហើយដល់ព្រះទក្ខិណេយ្យបុគ្គល ដែលមាននៅក្នុងជីវលោកនេះ រមែងជាទានមានផលច្រើន ដូចពូជដែលគេសាបព្រោះបណ្ដុះក្នុងស្រែដែលមានដីជាតិល្អដូច្នោះឯង" ។

ព្រោះដូច្នោះ ទានៈការឲ្យក៏គឺការបែងចែករំលែកសេចក្ដីសុខរបស់ខ្លួនដល់អ្នកដទៃ ឈ្មោះថាជាអ្នកប្រតិបត្តិប្រពៃ ឲ្យដោយមិនបៀតបៀនខ្លួននិងអ្នកដទៃ ជាអរិយសប្បុរិសប្បវេណីពីមុនមក ។ តាមពិតទានវត្ថុនេះ ពុទ្ធបរិស័ទមិនគួរប្រមាទ មានតិចឲ្យតិចមានច្រើនឲ្យច្រើន តាមសមគួរដល់កំឡាំងដែលល្មមធ្វើបាន សូម្បីក្នុងបុគ្គលជាន់ទាប ដូចយ៉ាងអ្នកកំសត់ទុគ៌ត យាចក វណិព្វកៈ អ្នកសូមសូមទានជាអ្នកអត់ឃ្លាន គ្មានទីពឹងពំនាក់អាស្រ័យ រហូតដល់សាធុជនជាន់ខ្ពស់ ដែលបរិបូណ៌ដោយសីលធម៌ ។

ទានដែលបុគ្គលបានឲ្យហើយទាំងនោះ រមែងមិនឥតផល និងជាអនុគាមិនី ជាប់តាមខ្លួនទៅក្នុងបរភពខាងមុខ នាំមកនូវសុខចំរើនកើនប្រយោជន៍និងកិត្តិគុណ កិត្តិសព្ទ កិត្តិយស កេរ្តិ៍ឈ្មោះ ល្បោះសំឡេង ក្រអូបឈ្ងុយឈ្ងប់គ្រប់ដំបន់ សម្បូណ៌ពោរសម្បើមដោយសម្បត្តិព្រះសុគតត្រាស់សរសើរទុកថា

"មនាបទាយី លភតេ មនាបំ អគ្គស្សទាតា លភតេ បុនគ្គំ វរស្ស ទាតា វរលាភី ច ហោតិ សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ" ។

*"អ្នកឲ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត, អ្នកឲ្យនូវវត្ថុដ៏លើសលប់ រមែងបាននូវវត្ថុដ៏លើសលប់, អ្នកឲ្យរបស់ល្អស្អាត រមែងបានរបស់ល្អស្អាត, អ្នកឲ្យទីឋានដ៏ប្រសើរ រមែងចូលទៅដល់ទីឋានដ៏ប្រសើរ, នរជនប្រុសស្រីឯណា ឲ្យរបស់ដែលលើស ឲ្យរបស់ដែលល្អ និងទីឋានដ៏ប្រសើរ; នរជនប្រុសស្រីនោះកើតក្នុងទីណាៗ រមែងជាអ្នកមានអាយុយឺនយូរ មានយសស័ក្តិក្នុងទីនោះៗមិនខានឡើយ"* ។

អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ
សេយ្យាវសថំ បទីបេយ្យំ ទានវត្ថូ ឥមេ ទស

*បាយ ទឹក សំពត់ យាន កម្រងផ្កា មាលាគន្ធាគ្រឿងលាបផ្សេងៗ*
*ទីដេកទីអាក់អឹកទីកន្ទ្រង ប្រទីបភ្លើងចង្កៀងនានា ។*
*ទាំង១០យ៉ាងនេះជាវត្ថុទាន អ្នកមានធនធានទឹងមានសទ្ធា*
*ទឹងបង់បានសុខសាន្តសព្វវេលា អញ្ជើញម្នម្នាបរិច្ចាគកុំខាន ។*

អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ

យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ
យោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ
អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ

អ្នកឲ្យបាយ ឈ្មោះថាបានឲ្យកំឡាំង
ឲ្យសំពត់បិទបាំង ឈ្មោះថាឲ្យពណ៌កាយ
ឲ្យយានជំនិះ ឈ្មោះថាឲ្យសុខសប្បាយ
ឲ្យប្រទីបភ្លឺស្វាយម៉ាយថាឲ្យចក្ខុ ។
អ្នកណាឲ្យទីដាក់សំណាក់ពាក់អាស្រ័យ
ឈ្មោះថាឲ្យបច្ច័យទាំងគ្រប់ប្រការ
អ្នកណាប្រៀនប្រៀនប្រដៅធម៌អាថ៌
អ្នកនោះឈ្មោះថាឲ្យនិព្វានបានប្រសើរ" ។

កាលអធិប្បាយដល់ការឲ្យ ហេតុដល់វត្ថុនិងបុគ្គលដែលគួរឲ្យដូច នេះ នាំឲ្យឃើញថា ទានជាគ្រឿងសំដៅ នៃសេចក្ដីមេត្តាករុណា សេចក្ដីមេត្រីកប់អាន , សេចក្ដីកតញ្ញូកតវេទីនិងសេចក្ដីគោរពគុណ ធម៌របស់មនុស្សដែលត្រូវពឹងពាក់ពំនាក់អាស្រ័យគ្នានិងគ្នា ធ្វើឲ្យមនុស្ស ដឹងថា ខ្លួនមិនរស់នៅតែលតោលតែឯកឯងក្នុងលោក ដូចេ្ន ព្រះពុទ្ធជាម្ចាស់ ទើបត្រាស់ចាត់ទានទុកជាធម៌ខាងដើម ល្អនិងលា

ជួមចិត្តសត្វ ឲ្យលះបោលគំនិត ដែលគិតតែរកប្រឡង់បង់ចុះតែខ្លួនមួយ ៗ ឲ្យបេះដូងអនុគ្រោះសង្គ្រោះចំពោះគ្នានឹងគ្នា ។

តែថា ការចែកចាយផ្សាយឲ្យអំណោយវត្ថុនេះនោះ ជាការអនុគ្រោះសង្គ្រោះគ្នានឹងគ្នានោះ នៅមិនទាន់អាចធ្វើមនុស្សឲ្យអស់សេចក្ដីក្រក់ទៅបានឡើយ ព្រោះជនខ្លះ សំឡាប់កាប់សំឡេះ អាយុជីវិតគេ ឬលួចប្លន់ឆបោកគេ យកមកធ្វើទានក៏មាន ៗ ហេតុនេះ ទើបត្រូវមានធម៌ជាខ្ទប់ប្រតិបត្តិបន្ទាប់ជាប់បន្តដំណ អំពីទានមកទៀត គឺ "សីល" សំរាប់ការពារសេចក្ដីក្រក់ផ្សេងៗដែលមនុស្សអ្នកធ្លាក់ចុះនៅក្រោមអំណាច នៃលោភៈ ទោសៈ មោហៈ គប្បីធ្វើតាមផ្លូវកាយវាចា ដែលនឹងទេសនាតទៅនេះ ៗ

## ២.សីលៈ

លោកព្រះពុទ្ធឃោសាចារ្យ អង្គប្រាជ្ញជាតិជម្ពូទ្វីបអ្នករចនាគម្ពីរភាសាមគធៈ ថែកព្រះពុទ្ធសាសនាជាច្រើន បានសរសេរទុកក្នុងសៀវភៅបករណវិសេសៈវិសុទ្ធិមគ្គថា "ឈ្មោះថាសីល" ព្រោះអត្ថថាយ៉ាងណា ? ព្រោះអត្ថថា "ប្រក្រតី" ៗ ពាក្យថាប្រក្រតី មានសេចក្ដីអធិប្បាយថា ការរក្សាកាយវាចាឲ្យសុភាពរាបសារ មានរបៀបរៀបរយប៉ះខបមៀម ស្រគត់ស្រគំសំណាំសំនួន មិនរំជួល មិនជ្រួលជ្រើម មិនក្រឡេមក្រឡឹម មិនក្រអាងក្រអឺតមិនឡូត ប្រឡោះបោះប្រឡានខាម ធ្វើតាម

ប្រក្រតីនៃល្អយ៉ាងណា ក៏នៅជាយ៉ាងនោះ មិនសស្រើកសស្រាក់ ដោយអំណាចជាអ្នកស្ងប់ស្ងៀមស្ងាត់ ១ ។ ដោយអត្ថថា "ទ្រទ្រង់ទុក" អធិប្បាយថា បើបុគ្គលរក្សាកាយ វាចា ឲ្យបានត្រឹមត្រូវតាមសីលចរិយា ហើយ អាចធ្វើឲ្យកុសលដទៃ ៗ ដូចបំរើនកម្មដ្ឋានជាដើមបានដោយងាយ ១ ។ អ្នកប្រាជ្ញអ្នកដឹងលក្ខណៈនៃសព្ទអនុញ្ញាតិអត្ថតែពីរនេះប៉ុណ្ណោះ ។ ×

យ៉ាងណាក៏ដោយ តាមដែលយើងជាប់ដឹងហើយ សីលគឺការរក្សាកាយ វាចា ឲ្យជាប្រក្រតី រៀបរយឬការវៀរចាកសេចក្តីអាក្រក់ផ្សេង ៗដែលមនុស្សតែងធ្វើតាមផ្លូវកាយនិងវាចា ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ជ្រាបច្បាស់ថា ការកេណ្ឌប្រមូលដឹកនាំឲ្យមនុស្សទាំងអស់ មានសេចក្តីប្រព្រឹត្តិល្អដល់ខ្នាត ស្មើ ៗ ដូច ៗ គ្នាទាំងអស់មិនបាន ទើបទ្រង់ទូន្មានទុក ទាំងជាន់ទាប ជាន់កណ្តាល ជាន់ខ្ពស់ ៗ ដោយហេតុនេះ បើជាគ្រហស្ថ ក៏ប្រដៅឲ្យរក្សាសីល ៥ ខ្លះ សីល ៨ ខ្លះ បើជាសាមណេរ ក៏ឲ្យរក្សាសីល ១០ ជាភិក្ខុក៏ឲ្យរក្សាសីលសិក្ខាបទ ២២៧ ។

សីលដទៃ ៗ សូមលើកទុក មកពិចារណាមើលតែត្រឹមសីល ៥ ដែលហៅថា និច្ចសីល គឺសីលដែលគួររក្សាជានិច្ច ក៏នឹងឃើញបានថា តាំងពីខទី ១ ដល់ទី ៥ដែលទូន្មានប្រៀនប្រដៅឲ្យវៀរចាកការបៀតបៀន

សំឡាប់ជីវិតសត្វ លួចប្លន់ ទ្រព្យសម្បត្តិរបស់អ្នកដទៃ ប្រព្រឹត្តខុសកន្លងច្បាប់ តាមប្រវេណីនឹងកូនប្រពន្ធអ្នកដទៃ ពោលពាក្យកុហកកួតករ រួមទាំង ៤ យ៉ាងនេះ ជាចំណែកដម្បូន្មាន ឲ្យវៀរចាកការធ្វើជាអំពើប្រព្រឹត្តទៅ ដើម្បីបៀតបៀន សត្វដទៃមនុស្សដទៃ ជាការប្រៀនប្រដៅឲ្យឃើញចិត្តនៃគ្នានឹងគ្នា ដោយលើកខ្លួនឡើងប្រៀបធៀបថា

"យើងត្រូវការចង់បានសេចក្ដីសុខកាយសប្បាយចិត្ត ឥតចង់ឲ្យនរណាមកបៀតបៀនសំឡាប់ជីវិតយើង មិនចង់ឲ្យនរណាមកលួចប្លន់ទ្រព្យសម្បត្តិយើង មិនចង់ឲ្យនរណា ប្រព្រឹត្តកន្លងការលោកិយ នឹងស្រីជាកូនប្រពន្ធយើង នឹងមិនចង់ឲ្យនរណានិយាយកួតករកុហកយើងយ៉ាងណា សូម្បីមនុស្សសត្វដទៃក៏មានចិត្តគំនិតគិតបំណង ដូចជាយើងដែរ" កាលបើដូចនេះ មិនគួរបៀតបៀនគ្នានឹងគ្នាឡើយ ។

សព្វេ តសន្តិ ទណ្ឌស្ស, សព្វេ ភាយន្តិ មច្ចុនោ,
អត្តានំ ឧបមំ កត្វា, ន ហនេយ្យ ន ឃាតយេ

" សព្វសត្វទូទៅនៅក្នុងភពវដ្ត សុទ្ធតែតក់ស្លុតរន្ធត់ភាញ
សុទ្ធតែខ្លាចស្លាប់គ្រប់ ៗ រូបា សុទ្ធតែប្រាថ្នារស់នៅគ្រប់គ្នា;
ព្រោះជីវិតជាទីស្រឡាញ់ស្និទ្ធ ឥតចង់ឲ្យនរណាមកផ្ដន្ទា
គួរធ្វើខ្លួនឲ្យជាឧបមា កុំប្រហារគេកុំប្រើគេធ្វើ "

បំណែកសីលទី៥ នោះ ប្រៀនប្រដៅឲ្យវៀរចាកការផឹកសុរាមេរ័យ និងទឹកស្រវឹងផ្សេងៗ ដែលជាការបៀតបៀនខ្លួនឯង ។ សីលខនេះ ជាទីទំនាស់ទាស់ចិត្តដល់អ្នកប្រមឹកផឹកស៊ីទាំងឡាយពេកណាស់ ; ជនពួកខ្លះ ដល់វេលាទទួលសីល ព្រមទទួលគ្រប់ខទាំងអស់ លុះដល់ខទី៥ ត្រឡប់អង្គុយប្រណម្យដៃ ងើយព្រងើយស្ងៀមទៅក៏មាន; យ៉ាងណាក៏ដោយការផឹកសុរាជាការប្រព្រឹត្តទៅ ដើម្បីផុតកំដៅបៀតបៀនខ្លួនឯងដោយពិត តាំងតែពីធ្វើឲ្យវិនាសហិនហែហិនហោចហិន-ហាយទ៍អន្តរាយខូចទ្រព្យសម្បត្តិ ជាដើមហេតុឲ្យធ្វើអំពើអាក្រក់ផ្សេងៗ ដែលមនុស្សធម្មតាមិនគួរធ្វើ ; មនុស្សដែលមានប្រាក់ចាយមិនគ្រប់គ្រាន់ ព្រោះហេតុប្រើទៅក្នុងផ្លូវផឹកសុរាក៏មានមិនតិច មនុស្សដែលធ្វើខុសច្បាប់អាជ្ញាអាណាចក្រ ព្រោះវង្វេងសុរាក៏មានជាច្រើនដោយវង្វេងសុរានេះ បុគ្គលអាចលក់ម៉ែលក់ឪបានទាំងអស់ ព្រោះក្នុងវេលានោះ សេចក្ដីដឹងខុសត្រូវទាំងឡាយ បានធ្លាក់នៅក្រោមអំណាចរបស់សុរាអស់ហើយ ខ្លះធ្លាប់ជាមនុស្សទឹងទូន ត្រឹមត្រូវ និយាយតិច លុះសុរាចូលដល់កាលណា ក៏ក្លាយទៅជាមនុស្សពេហ៍ៈ និយាយពាសវាល ផ្ដេសផ្ដាស ពាលផាលមិនបានការ ប្រហែលគ្នានឹងមនុស្សឆ្កួត សមនឹងពាក្យថា "សុរានិយាយមិនមែនមនុស្សនិយាយ សុរាធ្វើមិនមែនមនុស្សធ្វើ"

ហេតុនេះ ការវៀរចាកសុរា ក៏គឺការកាត់បំបាត់ដើមហេតុ ៈ

សេចក្ដីអាក្រក់គ្រប់យ៉ាង ៗ មនុស្សខ្វះអាងថា ផឹកល្មមតែប្រមាណ មិនជាអ្វីទេ តែបើសង្កេតមើលឲ្យល្អហើយ នឹងឃើញបានថា មនុស្ស ទាំងអស់ ធ្វើអ្វី ៗ សុទ្ធតែតិច ៗ ឬដឹងប្រមាណជាមុនទាំងអស់ លុះ យូរ ៗ មក សេចក្ដីដឹងប្រមាណក៏ភ្លេចភ្លាំងអស់ទៅ ប៉ុន្មាន ៗ ក៏មិន ល្មម ប៉ុន្មាន ៗ ពែង ក៏មិនចេះឆ្អែត ប៉ុន្មាន ៗ កែវ ក៏មិនចេះគ្រាន់ នេះ ក៏គឺការច្រើនមកអំពីតិច ការធ្លាប់មកអំពីហាត់ ។

"លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក
ផឹកស្រាធ្លាប់ស្រេក ជជែកធ្លាប់មាត់"

ទោសនៃការផឹកសុរា មានច្រើនប្រការ ខ្ញុំនឹងនិពន្ធ ជាពាក្យ កាព្យដូចតទៅនេះ:—

អ្នកប្រមឹក ផឹកសុរា នឹងមេរ័យ
តែងហិនហោច ខូចហិនហែ ទ្រព្យសម្បត្តិ
រលុតប៉ុង រលីងខ្ចាយ រលាយខ្ចាត់
វិនាសបង់ វិនាសបាត់ ឥតសេសសល់ ។
អ្នកប្រមឹក តែងប្រមូល ចូលចិត្តឈ្លោះ
ពោលគំរោះ ពាក្យគំរក់ ឈាមកខ្វល់
ជេរបញ្ឆោះ ឈ្លោះបញ្ចោរ កោលាហល
កើតក្ដីក្ដាំ នាំបឹងផ្ដល់ ដល់រដ្ឋបាល ។

អ្នកប្រមឹក ផឹកសុរា គ្នាជាប់ជោក
បណ្តាលពេក បណ្តុះរូប ឲ្យពិការ
ឲ្យក្តៅហួស ឲ្យជ្រួសហល់ រូបសង្ខារ
ឲ្យងងឹត ខូចវិចា រណញ្ញាណ ។
អ្នកប្រមឹក តែងស្អុយខ្ទូច ហោចកេរ្តិ៍ឈ្មោះ
ព្រសាយសុះ ថាជាមនុស្ស ទ្រុស្តឈ្មោទពាន
ដើរផ្តេសផ្តាស ពាសទិសទី ដូចតិរច្ឆាន
អ្នកអាងប្រាណ បែកព្រោកប្រាជ្ញ ឥតខ្លាចអ្វី ។
ឥតអៀនខ្មាស ឥតបិទបាំង បនគួរបិទ
ជាមនុស្សផិត ជាមនុស្សផុត ជោគពាសី
ធ្វើបញ្ញា ឲ្យអន់ថុះ ឲ្យតុះខ្វី
ធ្វើស្មារតី ឲ្យវ័ង្វន ភ័ន្តវង្វេង ។
ការប្រមឹក ជាប្រមុខ ឆ្គួតលីលា
ធ្វើបុកពារ ឲ្យថោកទាប ភាពអ្នកលេង
ដើរដជ្រែក មមកជ្រុល វ៉ៃបុកវៃជ្រង
តែម្នាក់ឯង ដើរផ្លូវមួយ ពោលទ្រគោះ ។
ពោលអំនួត អួតអំណាច រឿងកាចកោង
បុកក្រអោង កោងក្រអឺត ប្រឡោះពោះ

ដើរធ្លាក់ថ្មុក ជង្ហុកបឹង ត្រពាំងជ្រោះ
ពោលឡេះឡោះ ស្រែកឡូឡា ឮឡូនឡាន ៗ
វ៉ែបញ្ញោះ ឈ្មោះបញ្ញោរ កូនប្រពន្ធ
ជេរបន្អន់ ពោលបន្អាប់ ស័ព្ទក្អេងក្អាង
កាយបានផ្គាំង ប៉ុនប៉ាំងវែក ក្រឡថ្ងាង
មាត់រ៉ូងក៉ង ឮរូសក៉ស ពាសពេញស្រុក ៗ
ក្អកបង្អោរ ធុំបង្អាប ក្លិនអសោចិ៍
ដូចជាខ្មោច ហូរគម្រង់ សែនអផ្សុក
ជួនដេកជួល ដោយដងព្រៃ ស៊ុកម៉ុក
ជួនគក្រុក ដើរទទ្រេក ញាប់ញ័រកាយ ៗ
កាសដៃជើង ឡើងជំនោរ ជោរចំណាប់
អួតបាក់កាប់ គាំងតែស្លាប់ ឥតសោកស្តាយ
ឈប់ស្គាល់កូន ចៅប្រពន្ធ ឪពុកម្តាយ
ហ៊ានមើលងាយ កាយជេរលោក អ្នកមានគុណ ៗ
ប្រឡំឪ ថាជាពួក ម៉ាកគឿនផឹក
ឃើញមុខម៉ែ បែរជាទឹក ម៉ាប្រពន្ធ
ត្រង់មិនគួរ ថាជាគួរ បាបជាបុណ្យ
ទោសជាគុណ បុណ្យជាបាប សាបជាប្រៃ ៗ

ការប្រមឹក នាំប្រមាទ ខាតកុសល
នាំអំពល់ ផលអំពើ ប្រសើរក្រៃ
នាំបានទុក្ខ បុកម្នេញ ពេញផ្ទងចៃ
នាំចង្រៃ នាំបង្រាស ប្រាសព្រាត់គ្នា ៗ
នាំថោកទាប ត្រកូលញាតិ ជាតិផៅពង្ស
នាំឲ្យល្ងើ ភ្លើឲ្យល្ងង់ ឆ្គតពាលា
នាំគេខ្ពើម ល្អើមល្អូមស្អប់ គេនិន្ទា
នាំវេក ចងពៀរគ្នា ជាអង្វែង ៗ
នាំលាក់កាប់ នាំជាប់គុក នរកគោក
នាំឲ្យសោក រិះសោកសៅ យំសស្រែង
នាំអន់អប្ប យ៉ាប់កេរ្តិ៍ឈ្មោះ យូរអង្វែង
នាំឲ្យក្ដី វែងកោតក្រែង វែងគោរព ៗ
ការប្រមឹក ជាប្រមុខ ទុក្ខបបុប្បន្ទ
ឃើញស្រួកន់ ពន់ហន់ណាស់ គួរតែឈប់
ឯបរលោក ធ្លាក់ទៅកាន់ ទុគ្គតិភព
គួរកុំផប់ ជាប់សុក ណាខ្មែរអើយ !!!

រួមសេចក្ដី: សីលនោះ កំណត់ប្រតិបត្តិ ដើម្បីមិនបៀតបៀន អ្នកដទៃទាំងខ្លួនឯង ធ្វើឲ្យមនុស្សមានកាយវាចា សុភាព រាបសាល្អ

ព្រោះឆ្ងាយចាកសេចក្ដីអាក្រក់ ធ្វើឲ្យពិភពលោក តាំងនៅដោយសេចក្ដីស្ងប់រៀបរយ ឲ្យជនឲ្យឃើញចិត្តនៃគ្នានឹងគ្នា ធ្វើឲ្យរលត់ព្យាបាទរបស់សត្វលោកអន់ថយកំឡាំងចុះ លោកទើបចាត់ទុកជាធម៌ លំដាប់ទី ២ ដំណអំពីទាន ។

មានពាក្យពោលសរសើរថា "ពន្លឺព្រះចន្ទ ក៏មិនត្រជាក់ស្មើនឹងសីល ព្រោះពន្លឺព្រះចន្ទត្រជាក់បានត្រឹមតែក្លុកប៉ុណ្ណោះ ចំណែកសីលទើបត្រជាក់ត្រជុំស្ងប់ចូលដល់បេះដូង ។ ស្ទឹងធំ ៗ ប៉ុន្មានក៏ដោយ ដែលជាតិសាសន៍ខ្លះ ជឿកាន់រាប់អានថា អាចលាងបាបបាន ទុកជាងូតមួយថ្ងៃ ៣ ដង ឬ ងូតរាល់ល្ងាចក៏ដោយ ក៏លាងបានតែមន្ទិលខាងក្រៅប៉ុណ្ណោះ ចំណែកសីលវិញ ទើបអាចលាងមន្ទិលខាងក្នុង គឺសេចក្ដីប្រព្រឹត្តអាក្រក់បានពិត ៗ ធ្វើកាយវាចាឲ្យរៀបរយ ព្រោះដូច្នោះ ស្ទឹងគឺសីលទើបប្រសើរជាងស្ទឹងទាំងពួង ។

ពុទ្ធភាសិតថា៖

អប្បមត្តោ អយំ គន្ធោ យាយំ តគរចន្ទនំ
យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ

"ក្លិននៃខ្លឹមចន្ទន៍នឹងក្រស្នា ក្លិននេះជម្ពាមិនប្រមាណ
ចំណែកប៉ែកក្លិននៃអ្នកមាន សីលកល្យាណផងទាំងឡាយ

នោះទើបក្រអួបក្រអែបឈ្ងប់ ឈ្ងុយឆ្ងាញ់ខ្ពស់លប់ព្រួខ្ចាយ
ទៅក្នុងទេពតាមនុស្សទាំងឡាយ សុះសាយកាយសព្វគ្រប់ទិសទី;

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ

"សេចក្តីរស់នៅត្រឹមតែមួយថ្ងៃ នៃអ្នកមានសីលនិងឈានឧត្តម
ក៏ប្រសើរជាងរស់នៅរយឆ្នាំ នៃអ្នកសាំញ៉ាំ គ្មានសីលចរិយា;

អ្នកឲ្យតានរក្សាសីល រមែងបានទទួលតែសេចក្តីស្ងប់ទោះនឹងទៅក្នុងទីណា ក៏ពេញទៅដោយមិត្តសំឡាញ់ដែលមានចិត្តមេត្រីរាប់អានគោរពកោតខ្លាចស្តាប់បង្គាប់ចូលទៅក្នុងសមាគមណា ៗ រមែងជាអ្នកក្លៀវក្លាអង់អាចឥតខ្លាចអ្វី រមែងបានសេចក្តីសុខកាយសប្បាយចិត្ត ពិតប្រាកដទាន់ភ្នែក លុះទម្លាយរាងកាយទៅកាន់បរលោកនាយ នឹងបានរីករាយសប្បាយសម្បូណ៌សម្បើមឆ្អែមដោយសម្បត្តិ ក្នុងឋានសួគ៌ទៀត ។ អ្នកដែលបានទៅកើតក្នុងឋានសួគ៌ ក៏ព្រោះធ្វើបុណ្យគឺតានសីលជាហេតុ ឋានសួគ៌ជាផលរបស់បុគ្គលដែលធ្វើតានសីលនោះឯង ដូចសំដែងថ្លែងសេចក្តីតទៅនេះ ៖

## ៣. សគ្គ:

ពាក្យមគធៈថា" សគ្គ: ពាក្យសំស្រ្កឹត "ស្វគ៌" ខ្មែរយើងតែងហៅថា "ឋានសួគ៌" តាមសេចក្តីជឿរបស់មនុស្សទូទៅ ថាឋានសួគ៌

ជាទីពេញដោយសេចក្ដីសុខ មានទេវបុត្រទេពធីតា ប្រចាំនៅក្នុងវិមានរបស់ខ្លួន ៗ ទីនេះត្រូវការអ្វីក៏សំរេចបាន សមដូចចិត្តប្រាថ្នា ពេញផ្អែតទៅដោយទិព្យសម្បត្តិ បរិបូណ៌ទៅដោយកាមគុណ ៥ គឺរូប សំឡេង ក្លិន រស សម្ផស្ស ជាទីរីករាយសប្បាយចិត្ត ។ ពាំងនេះដោយគ្រប់សាសនា សឹងពណ៌នាដល់ឋានសួគ៌ទុកដូចគ្នា ផ្សេងតែសាសនាខ្លះគេលើកយកសាស្ដាចារ្យ ឬ ទេវតារបស់ខ្លួនថាជាធំ ជាប្រធានរបស់ឋានសួគ៌នោះៗ ។ ចំណែកព្រះពុទ្ធសាសនា មិនបានប្រដៅអស់ផុតត្រឹមឋានសួគ៌ប៉ុណ្ណោះទេ នៅប្រដៅឲ្យមនុស្សមានធម៌របស់ទេវតា របស់ព្រហ្ម ទីងអប់រំបំពេញខ្លួន ដើម្បីជាអ្នកថ្លាថ្លៃក្រៃលែង ប្រសើរលើសទេវតាទីងព្រហ្ម ដោយគុណធម៌ខ្ពស់ឡើងទៅក៏មាន គឺយកឋានសួគ៌មកបៀបឲ្យឃើញថានៅក្នុងមនុស្សលោកនេះ ក៏មានទេវតាមានព្រហ្មដែរ ដោយលើកសេចក្ដីប្រព្រឹត្តឡើង បំបែកញែកមនុស្សឲ្យផ្សេងៗគ្នា ដូចមនុស្សនរក មនុស្សតិរច្ឆាន មនុស្សមនុស្ស មនុស្សទេវតា មនុស្សព្រហ្ម មនុស្សអរិយៈ នេះបញ្ជាក់ឲ្យឃើញស្រាយ ៗ ថា មនុស្សយើង អាចឡើងឋានសួគ៌ ឬធ្លាក់នរកទាំងរស់ដោយសេចក្ដីប្រព្រឹត្តនេះឯង ។

មនុស្សដែលធ្លាប់ប្រព្រឹត្តសុចរិតធម៌ សន្សំកសាងធ្វើអំពើល្អ រមែងបានទទួលសេចក្ដីសុខផ្អែតចិត្ត តាំងតែពីមានជីវិតរស់នៅ ទីងហៅថាឡើងឋានសួគ៌ទាំងរស់ក៏បាន ។ មានផ្លូវសន្និដ្ឋាន រឿងសុគតិ ទុគតិ

ធៀបនរក ឋានសួគ៌ ឋានមួយផ្សេង ៗ រឿងឋានសួគ៌ពិតៗនោះលោក ថាអ្នកធ្វើចិត្តឲ្យជា សមាធិ រហូតបានទិព្វចក្ខុ ទើបអាចឃើញបាន ព្រោះជាឋានដែលមានខន្ធធាតុ អាយតនៈផ្សេងគ្នាពីមនុស្ស ទើបមិនជា វិស័យរបស់មនុស្ស គប្បីឃើញបានឡើយ តែបើនិយាយឲ្យស្តាប់ងាយ ត្រូវលើកហេតុផលដែលប្រាកដដល់ភ្នែកមកនិយាយគ្នា ។

បណ្ឌិតចិត្តសាស្ត្រម្នាក់ ស៊ិនដ្ឋាន រឿងមនុស្សស្លាប់ហើយកើត ទៀត ដោយលើកហេតុផលយ៉ាងនេះ ជាដើមថា "ការដែល ក្មេងបេះបៅដោះនឹងសំដែងសេចក្តីពេញចិត្តនឹងមិនពេញចិត្ត ដោយការ សើចឬយំ ដោយមិនបាច់នរណាបង្រៀនប្រដៅ ដូចនេះបញ្ជាក់ថា ក្មេង នោះធ្លាប់ធ្វើដូច្នោះមកហើយអំពីជាតិមុន; ការដែលមនុស្សមិនធ្លាប់ ស្គាល់គ្នា អំពីវេលាមុនលុះឃើញគ្នាភ្លាម ក៏ស្រាប់តែជាប់ចិត្តចូលចិត្ត ស្រឡាញ់ឬស្អប់ខ្ពើម នេះសំដែងឲ្យឃើញថា មនុស្សនោះៗធ្លាប់ជាមិត្ត ឬជាសត្រូវនឹងគ្នា មកអំពីជាតិមុន; ក្មេងអ្នករៀនក្នុងថ្នាក់មួយៗមាន សេចក្តីអង់អាចឬពេញចិត្តក្នុងវិជ្ជាផ្សេងៗគ្នា នេះសំដែងឲ្យឃើញថា ក្មេងនោះៗ ធ្លាប់ចូលចិត្តឬស្ទាត់ជំនាញចំណាន ក្នុងវិជ្ជានោះៗ មក ហើយអំពីជាតិមុន មិនមែនដូចគ្នា ។

មានរឿងមួយ ដែលនានាប្រទេស បានបោះពុម្ពផ្សាយ គឺ អធិប្បាយដំណាលអំពីក្មេងស្រីម្នាក់ នៅក្នុងប្រទេសឥណ្ឌា កាលពី

ឆាត់វឌ្ឍនាការល្មមចាំសេចក្ដីបាន ក៏រលឹកជាតិឃើញថា ខ្លួនធ្លាប់កើតជាកិរិយារបស់បុរសម្នាក់ នៅក្នុងដំបន់មួយ ៗ ក្មេងនោះចាំបានថា ខ្លួនមានកូនប្រុសស្រីប៉ុណ្ណេះប៉ុណ្ណោះនិងមានឈ្មោះ យ៉ាងនេះ ៗ ផង ៗ

ញាតិជាធំ របស់ក្មេងស្រីនោះ ចង់ពិសោធកាត់សេចក្ដីពិតឲ្យដឹងថាមែនឬមិនមែន ; ទើបនាំកុមារីនោះ ទៅកាន់ស្រុកជាតិមុន ឡើងរថភ្លើងនៅឋានីយ៍ណា ក៏ឲ្យក្មេងស្រីនោះនាំទៅ ហើយត្រូវឈប់នៅត្រង់ឋានីយ៍ណា ក៏ឲ្យក្មេងស្រីនោះប្រាប់ ចុះពីរថភ្លើងទៅ និងកាលឡើងរថយន្ត ទៅចុះត្រង់ស្រុកដើម នៅត្រង់ណោះត្រង់ណោះ ក៏ឲ្យក្មេងស្រីនោះជាអ្នកនាំទាំងអស់ ក្មេងស្រីនោះ បាននាំដកបពាល់តែដល់ស្រុកជាតិមុន ទើបសាកសួរទៅក៏បានដឹងថា មានប្រុសម្នាក់ឈ្មោះនោះ ៗ ធ្លាប់មានកិរិយាស្លាប់ទៅពិត ៗ ពិនិត្យសាកសួរសព្វគ្រប់ ក៏ត្រូវតាមសំដីក្មេងស្រីនោះនិយាយទាំងអស់ ; ទាំងនេះជាហេតុផលក្នុងរឿងមនុស្សស្លាប់ហើយកើតទៀត ដែលល្មមចូលចិត្តបានដោយងាយ ៗ

ពាក្យថា "គតិ" ប្រែថា "ដំណើរដើរទៅឬផ្លូវទៅ" សុគតិ គឺដំណើរផ្លូវទៅល្អ , ទុគ្គតិ គឺដំណើរទៅមិនល្អ កាលចូលចិត្តថា មនុស្សសត្វស្លាប់ហើយត្រូវកើតទៀត ការដែលកើតនោះ ទើបឈ្មោះថាជាគតិរបស់មនុស្ស បើទៅកើតជាសត្វតិរច្ឆាន នរក ប្រេត អសុរកាយក្ដី កើតក្នុងឋានៈ ដែលលំបាកយ៉ាកយ៉ាប់អព្វមង្គល ទុព្វលភាព

ទាបថោកក្តី មានអវយវៈខ្វះខ្វិត ខ្វាក់ខ្វិន ថ្លង់ គ គមគាក់ បិទ្បឺ បឹទ្បឺ ស្ទើស្ទឺ ល្ងីល្ងើ កំពី កំពួ កំពក កំពុក ក្រពិត ក្រប៉ូវ ក្រញ៉ូវ ក្រញ៉ាង ក្រញើស ទាបក្រញ៉ុញ មុខញ៉ុញប្រមុញ ពងរ៉ាវប្រែខាវ ដូចខ្មោចលងក្តី ឈ្មោះថាជាទុគ្គតិ សំរាប់មនុស្សអ្នកស្លាប់នោះ ៗ បើកើតក្នុងឋានៈដែលល្អ មានសេចក្តីសុខសម្រាន្ត ក្សាន្តសប្បាយ ក៏ចាត់ជា សុគតិ ៗ កាលសុគតិ ឬទុគ្គតិ មាននៅឃើញពិត ៗ ដូចនេះ ; អ្នកធ្វើអំពើល្អ និងអាក្រក់ទុក កាលស្លាប់ហើយកើតទៀត ក៏មុខជាទៅកាន់សុគតិឬទុគ្គតិ តាមអំពើដែលខ្លួនធ្វើទុកអំពីមុន ៗ នេះជារឿងសុគតិ ទុគ្គតិ ល្មមគិតឲ្យបូលចិត្តថា នរក សួគ៌ មានពិតប្រាកដ តាំងបច្ចុប្បន្ន ឥធលោក និងបរលោក ៗ

សូមពន្យល់ម្តងទៀត : ពាក្យថា " សួគ៌ " ស័ព្ទដើមជាភាសាមគធ: ថា សគ្គ: " ពាក្យនេះញែកទៅជាពីរគឺ ស + គ្គ: " ស " ស័ព្ទដើមជា " សុ " ប្រែថា " ល្អ ស្អាត ឆ្ងាយ " ៗ " គ្គ " ស័ព្ទដើមជា " អគ្គ: " ប្រែថា " ចុង កំពូល លើស " រួមជា " សគ្គ: " ប្រែថាល្អលើស ស្អាតលើស ឆ្ងាយលើស ; សំដៅសេចក្តីថា ល្អលើស ស្អាតលើសក្នុងផ្លូវលោក គឺក្នុងផ្លូវរូប សំឡេង ក្លិន រស សម្ផស្ស ទ្រព្យ យស សុខ សរសើរ អាយុ វណ្ណ: ជាដើម តាមលោកនិយម ៗ ឆ្ងាយលើស គឺឆ្ងាយក្នុងផ្លូវលោក ចិត្តបំណង ចង់ បានអ្វីក៏បាន ឆ្ងាយ ៗ ក្សេម ៗ

សមដូចបំណងប៉ងប្រាថ្នា ។

ពួកទេវតា ដែលនៅក្នុងឋានសួគ៌ សុតសឹងតែមានសេចក្ដីសុខដ៏លើស តាមថ្នាក់-ជាន់; អ្វីៗ ក៏សុតតែល្អស្អាតលើស ជាទីភ្លើតភ្លើនបំពេន ចិត្តគ្រប់យ៉ាង ដូចរូបក៏ល្អល្អះ ត្រចង់ត្រចះ សំឡេងក៏ពិរោះផ្អែមល្ហែម ជាប់ចិត្ត ក្លិនក៏ក្រអូបក្រអែបឈ្ងុយឈ្ងប់ រសក៏មានបម្ញាញ់ឆ្ងាញ់ចំណាប់ សម្ផស្សក៏ទន់ល្វតល្វន់ រលើងរលោងរលើប គួរជាទីប៉ះពាល់ ; អ្វីៗ ទាំងអស់សុតតែល្អស្អាត ជាងរបស់មនុស្សទាំងពាន់ផង ។

អ្នកដែលនៅក្នុងឋានសួគ៌ជាន់នោះៗ ពីដើមកាលជាមនុស្ស ជាអ្នកមានសេចក្ដីប្រព្រឹត្តល្អ មានហិរិឱត្តប្បៈ អៀនខ្មាសខ្ទើមរអើមខ្លាចរអា មិនហ៊ានបំពានធ្វើអំពើបាបទុច្ចរិត ដោយកាយ វាចា ចិត្ត ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំង និងធ្វើតែអំពើល្អ មានទាន សីល ជាដើម កាលស្លាប់អំពីមនុស្ស ទើបបានទៅចាប់កំណើតកើតក្នុងឋានសួគ៌ ។

សូមអញ្ជើញពិនិត្យគិតមើលថា ផលរបស់ធម៌ទាំងពីរយ៉ាងនេះ តើយ៉ាងណា ក្នុងវេលាដែលយើងនៅជាមនុស្ស ? កាលពិនិត្យគិតមើលឲ្យមែនទែនហើយ នឹងឃើញបានថា ផលរបស់ធម៌ទាំងពីរយ៉ាងនេះគឺ សេចក្ដីសុខសប្បាយ ស្ងប់-ត្រជាក់ចិត្ត កាលនរណាមានធម៌ទាំងពីរយ៉ាងនេះ ប្រចាំនៅក្នុងចិត្តហើយ អាចរាប់បានថា នរនោះ

ទៅនៅក្នុងឋានសួគ៌ជាន់មនុស្ស ឬឈ្មោះថាបានទៅឋានសួគ៌ដោយចិត្ត ។

តាមដែលបរិយាយមកនេះ សូមឲ្យគិតមើលចុះថា កាលមានសេចក្តីល្អប្រចាំនៅក្នុងចិត្តដូចនេះហើយ តើមានសេចក្តីសុខឬគ្មាន ? បើនៅមិនទាន់ឃើញថា មានសេចក្តីសុខ សូមសង្កេតពិនិត្យមើលបន្តិចទៀត គឺឲ្យប្រៀបធៀបផ្គូផ្ទឹមខ្លួនយើងដែលធ្វើល្អ និងអ្នកដែលធ្វើអាក្រក់ថា ខាងណាបានសុខឬទុក្ខយ៉ាងណា ? កាលបានសង្កេតដូចនេះហើយ លោកអ្នកនឹងឃើញថា អ្នកធ្វើអំពើអាក្រក់ ត្រូវទទួលទុក្ខបុកម្នេញ ដក់ដើញ ក្តៅក្រហល់ក្រហាយ ស្តាយក្រោយសោយទុក្ខដល់ចិត្ត ពប់ថា ធ្លាក់នរកទាំងរស់ ។ ឯអ្នកធ្វើអំពើល្អ រមែងមានតែសេចក្តីរីករាយសប្បាយចិត្ត ត្រជាក់ត្រជុំសុខចិត្តជាដរាប ។

ម្យ៉ាងទៀត សូមឲ្យធៀបសេចក្តីសុខរបស់មនុស្សជាន់ខាងនិងមនុស្សជាន់ខ្ពស់ ឲ្យជាគំរូមើល គឺឲ្យធៀបខ្លួនយើងនឹងព្រះរាជា ព្រះអគ្គមហេសី ព្រះរាជបុត្រ ព្រះរាជធិតា ដែលលោកលើកដំកើងថា ជាសម្មតិទេវតា តើខាងណាមានសុខច្រើនជាងគ្នា ទីពេក, អា-ហារ, គ្រឿងស្លៀកពាក់ ចំណែកក របស់យើងនិងរបស់លោកទាំងនោះតើខាងណាថ្លៃថ្លាប្រសើរជាង ? កាលផ្គូផ្គងមើលយ៉ាងនេះហើយ នឹងឃើញបានថាសេចក្តីសុខរបស់មនុស្ស រមែងច្រើនជាងគ្នាជាជាន់ ៗ បើធៀបសុខរបស់មនុស្សនឹងសុខក្នុងឋានសួគ៌ ក៏សែន

ឆ្ងាយគ្នា យ៉ាងលន្ទឹមលន់ ប្រៀបដូចមេឃនឹងដី ពាក្យនេះព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកក្នុងឧបោសថសូត្រ ចំពោះមហាឧបាសិកា ឈ្មោះវិសាខាថា "បើធៀបសុខរបស់មនុស្សនឹងសុខក្នុងឋានសួគ៌ សុខរបស់មនុស្សមានប្រមាណតិចតួចស្តួចស្តើងពេកណាស់ បើធៀបអាយុក៏ខុសគ្នាជាច្រើនគឺ:

អាយុក្នុងឋានសួគ៌ ចាតុម្មហារាជិកា ៥០០ ឆ្នាំទិព្វគិតជាឆ្នាំក្នុងមនុស្ស បាន៩លានឆ្នាំ ; ៥០ ឆ្នាំមនុស្ស ជា ១ថ្ងៃ ១យប់ របស់ឋានសួគ៌ជាន់ចាតុម្មហារាជិកា ។

១០០ឆ្នាំមនុស្ស ជា១ថ្ងៃ១យប់ របស់ឋានសួគ៌ជាន់តាវត្តិំស ។ នោះ មានអាយុ១០០០ឆ្នាំទិព្វ គិតជាឆ្នាំក្នុងមនុស្ស បាន ៣ កោដិ ៦ លានឆ្នាំ ។

២០០ឆ្នាំមនុស្ស ជា ១ថ្ងៃ ១ យប់ របស់ឋានសួគ៌ជាន់យាមា ។ នោះ មានអាយុ ២០០០ ឆ្នាំទិព្វ គិតជាឆ្នាំក្នុងមនុស្សបាន១៤កោដិ ៤ លាន ឆ្នាំ ។

៤០០ឆ្នាំមនុស្សជា ១ ថ្ងៃ ១ យប់ របស់ឋានសួគ៌ជាន់តុសិត ។ នោះ មានអាយុ ៤០០០ ឆ្នាំទិព្វ គិតជាឆ្នាំក្នុងមនុស្ស បាន ៥៧ កោដិ ៦ លានឆ្នាំ ។

៨០០ ឆ្នាំមនុស្ស ជា ១ថ្ងៃ ១ យប់ របស់ឋានសួគ៌ជាន់និម្មាន-

រតី ១ នោះ មានអាយុ ៨០០០ ឆ្នាំទិព្វ គិតជាឆ្នាំក្នុងមនុស្ស បាន ២៣០ កោដិ ៤ លានឆ្នាំ ។

១៦០០ ឆ្នាំមនុស្ស ជា ១ ថ្ងៃ ១ យប់ របស់ឋានសួគ៌ជាន់បរ-និម្មិតវសវត្តី ១ នោះ មានអាយុ ១៨ ពាន់ឆ្នាំទិព្វ គិតជាឆ្នាំក្នុងមនុស្ស បាន ៩២១កោដិ៦ លានឆ្នាំ” ។

បើនិយាយដោយវណ្ណៈ គឺពណ៌សម្បុរកាយរបស់មនុស្ស ឬពណ៌សម្បុរគ្រឿងប្រដាប់ប្រដា របស់មនុស្សនិងរបស់ទេវតា ក៏ខុសគ្នាឆ្ងាយ ពណ៌សម្បុរកាយរបស់មនុស្ស ទុកជារលើង រលោង រលីប ល្អិត ល្អ ស ល្អះត្រចះត្រចង់យ៉ាងណាក៏ដោយ ក៏មិនអាចកំចាត់ងងឹតឲ្យភ្លឺស្វាងបានឡើយ ភ្លឺភ្លែត ១ បន្តិច ១ ដែរ ចំពោះតែគ្រឿងប្រដាប់ដែលធ្វើដោយពេជ្រប៉ុណ្ណោះ ចំណែកពណ៌សម្បុររបស់ទេវតា ទើបអាចកំចាត់ងងឹត ធ្វើទីដែលងងឹតឲ្យភ្លឺស្វាងបាន ដូចពាក្យដែលលោកពោលទុកថា មានពន្លឺរស្មី សរីរៈកាយផ្សាយទៅបាន ១២ យោជន៍ ឬដែលច្រកដកក្នុងខាងដើម នៃព្រះសូត្រផ្សេង ១ ដែលពោលដល់ទេវតា ចូលគាល់ព្រះពុទ្ធជាម្ចាស់ថា “ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា ទេវតា ទាំងឡាយ ញ៉ាំងវត្តជេតពនទាំងមូល ឲ្យភ្លឺស្វាងរុងរឿង ដោយពណ៌សម្បុរសរីរកាយនិងគ្រឿងប្រដាប់របស់ខ្លួន” ។

បំណែក សុខៈ ពលៈ និងអ្វី ៗ ផ្សេងទៀតរបស់មនុស្សនិងរបស់ទេវតា ក៏ត្រោតគ្រាតនឹងប្រណីតច្រើនជាងគ្នាជាបំផុត មិនឈ្មោះពណ៌នាឲ្យរប់សព្វគ្រប់ក្នុងឱកាសនេះបានឡើយ ។

ហានសង្គតិដែលអធិប្បាយមកដោយខ្លី ៗ នេះ ជាផលដែលត្រូវបានដល់អ្នកធ្វើបុណ្យ មានទានសីលជាដើមដូចថ្លែងរួចមកហើយ សមនឹងព្រះពុទ្ធភាសិតថា

ឥធ មោទតិ បេច្ច មោទតិ
កតបុញ្ញោ ឧភយត្ថ មោទតិ
សោ មោទតិ សោ បមោទតិ
ទិស្វា កម្មវិសុទ្ធិមត្តនោតិ ។

"បុគ្គលអ្នកធ្វើបុណ្យ ដែលជាគុណល្អតោមតាម
តែងបានសុខចិត្តកាយ រីករាយក្នុងឥធលោក ។
និងក្នុងលោកខាងនាយ សែនរីករាយដោយជ័យជោគ
សម្បូណ៌សម្បត្តិភោគ ដោយបុណ្យយោគយ៉ាងជួយប្រាណ
អ្នកធ្វើបុណ្យនោះ ៗ តែងប្រមនុស្សក្តីក្សេមក្សាន្ត
ព្រោះឃើញកម្មកល្យាណ បរិសុទ្ធរបស់ខ្លួន" ។

សត្តោ បសន្នោ អ៊ិត្ថិ មាតាបិត្តុំ [illegible]

សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ
សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ ។

"ពួកឈ្មួញជាមិត្តអ្នកដើរផ្លូវឆ្ងាយ មាតាគឺម្តាយជាមិត្តក្នុងផ្ទះ
សំឡាញ់តាំងឡាយជាមិត្តវិសេស ក្នុងកាលប្រទះកិច្ចការរឿយ ៗ ។
អំពើកុសលដែលគេប្រឹងប្រែង ធ្វើដោយខ្លួនឯងសន្សំទុកហើយ
ជាមិត្តវិសេសទៅបរលោកនាយ ជួយឲ្យរីករាយរុងរឿងរុងរោចន៍ ។

បុណ្យតែងអំណោយផលដល់អ្នកធ្វើ អ្នកធ្វើបុណ្យនេះមុខជានឹងបានទទួលបណ្ណាការរបស់បុណ្យ ១០ យ៉ាង គឺ អាយុទិព្វ ១ ពណ៌សម្បុរទិព្វ ១ សេចក្តីសុខទិព្វ ១ យសស័ក្តិទិព្វ ១ ភាពជាធំបានអំណាចទិព្វ ១ រូបទិព្វ ១ សំឡេងទិព្វ ១ ក្លិនទិព្វ ១ រសទិព្វ ១ សម្ផស្សទិព្វ ១ ។

បណ្ណាការរបស់បុណ្យនេះ ជាទីប្រាថ្នារបស់យើងគ្រប់គ្នា ព្រោះនាំឲ្យសម្បូណ៌សប្បាយរីករាយរុងរឿងឥតខ្ចះ នឹងរឿងកាមគុណទៀយ.

តែថា ការសប្បាយនឹងកាមគុណនេះ មិនមែនគង់វង់ ប្រាកដប្រជាថាវរៈ រហូតទៅទេ កាមគុណនេះតែកើតកើនកើបក្បាំង មុខជាឃ្លាតបានទុក្ខក្រាមមកដល់ខ្លួនមិនខាន បានជាព្រះពុទ្ធម្ចាស់ត្រាស់សំដែងពីទោសរបស់កាមតាមហេតុផល ដើម្បីកុំឲ្យសត្វឈ្លក់នឹងកាមគុណកើបខ្លួនពេក កុំឲ្យត្រេកត្រអាលងាល់តែយល់ថា បានសួគ៌ ជាកន្លែងសុខ មិនប្រែប្រួល

នោះឡើយ ហេតុនេះហើយ ទើបបានសំដែងទោសរបស់កាម តាមលំដាប់ធម៌ទី ៤ ដូចតទៅនេះ :

## ៥- កាមាទីនវៈ

មនុស្សលោកក្តី ឋានសួគ៌ដែលហៅថាទេវលោកក្តី លោកចាត់ជាកាមភព ៗ ចិត្តរបស់មនុស្សនិងទេពតាក្នុងកាមភពនេះ សឹងត្រឡប់ត្រឡិន អន្ទោកអន្ទាលនៅនឹងរឿងកាម ៗ ភូមិនៃចិត្តរបស់អ្នកកើតក្នុងកាមភព ដែលមិនទាន់បានលុះមគ្គផល លោកទើបហៅថាកាមាវចរភូមិ ៗ

កាលសេចក្តីសុខក្នុងកាម ជាសុខដែលគួររីករាយចិត្តថ្មើម របស់ពួកមនុស្សទេពតាក្នុងកាមភពនេះ ទើបឃើញបានថា កំពូលនៃសេចក្តីប្រាថ្នារបស់អ្នកកើតក្នុងកាមភព មិនមានអ្វីក្រៃលែងទៅជាងកាម គឺបំណង ៗ គួរពិចារណាពាក្យថា កាមឲ្យចូលចិត្តជាមុន កាមគឺបំណងនោះ ចែកជា ២ យ៉ាង គឺកិលេសកាម កិលេសជាគ្រឿងចង ១ វត្ថុកាម វត្ថុអារម្មណ៍ជាគ្រឿងចង ១ ៗ

អ្នកដែលជួបសេចក្តីសុខ យ៉ាងខ្ពស់ក្នុងកាមភព ក៏មិនមានអ្វីក្រៃលែងជាងសេចក្តីក្ទើតក្ទើន ត្រេកត្រអាលស្រើបស្រាល ក្នុងអារម្មណ៍ដែលខ្លួនបំណងប៉ងប្រាថ្នា អារម្មណ៍នោះ គឺរបស់ដែលឃើញដោយភ្នែក ១ ស្តាប់ដោយត្រចៀក ១ ធុំក្លិនបានដោយច្រមុះ ១

ដឹងជាតិរសដោយអណ្តាត ១ ប៉ះពាល់ដាល់ត្រូវដោយកាយ ១ ហៅខ្លី ៗ ថា រូប សំឡេង ក្លិន រស សម្ផស្ស ៗ សេចក្តីប្រាថ្នារបស់សត្វលោកដោយច្រើន ឬ ទាំងអស់ ក៏គឺអ្វីជារបស់ខ្លួន មិនថា បុត្រភរិយា ឬ ស្វាមី រហូតដល់គ្រឿង ប្រើប្រាស់ ក៏ចូលចិត្តតែល្អ ៗ ជាទីពេញភ្នែក សំឡេង ដែលបានឮ ក៏ចូលចិត្តតែសំឡេងពិរោះផ្អែមល្ហែម, ក្លិនក៏ចូលចិត្ត ហិត ថើបជុំ តែក្លិនក្រអូប ; រសក៏ចូលចិត្តតែឈ្ងុយឆ្ងាញ់ ឬ ផ្អែក ; បំណែកសម្ផស្ស ក៏ចូលចិត្តតែរលីងរលោងរលើប ៗ ការតែងខ្លួន ស្អាតល្អប្រិមប្រិយ ក៏ដើម្បីឲ្យត្រូវភ្នែកមនុស្សដទៃ ឬ ដើម្បីអួតសេចក្តីល្អ ដែលម្ចាស់ខ្លួននឹកថា ខ្លួនក៏ល្អដែរដូច្នេះជាដើម ។ល។

តាមដែលពោលមកហើយ ក៏ល្មមឃើញបានដល់ការដែលមនុស្ស ឬ ទេវតាពិត ៗ នាំគ្នាចូលចិត្តជក់ជាប់ជាប់ចំណង់ នឹងរូប សំឡេង ក្លិន រស សម្ផស្ស ដោះដៃមិនរួច ៗ មនុស្សចង់ទៅឋានសួគ៌ ក៏ដោយនឹកថា ឋានសួគ៌មានអារម្មណ៍ល្អលើសជាងមនុស្ស សូម្បីទេវតាឯងក៏មិនចង់ចេញចាកឋានសួគ៌ ព្រោះស្តាយ រូប សំឡេង ជាដើមជាទិព្វ ៗ តែឋានសួគ៌ក្តីជីវិតរបស់មនុស្ស ឬ ឋានសួគ៌ពិត ៗ របស់ទេវតាក្តី មានអ្វីដែលគង់វង់ឋិតថេរខ្លះ? អារម្មណ៍ផ្សេង ៗ ដែលគិតថាជាសុខនោះ ក៏ត្រឹមតែមួយពេលមួយខណៈប៉ុណ្ណោះ សូម្បីមិនវិនាសប្រាសព្រាត់ខ្ចាត់ខ្ចាយហាយនៈសូន្យទៅចាកយើងមុន ៈយើងក៏គង់

ត្រូវស្លាប់បាត់អារម្មណ៍ទាំងនោះទៅមុន សេចក្ដីសុខក្នុងលោក ជាសុខដែលបញ្ឆោតចិត្ត ព្រោះជាកាមសុខ គឺសុខព្រោះយើងចង់ កាលរបស់នោះវាប្រែប្រួលទៅក៏ធ្វើឲ្យសោកសៅក្ដៅក្រហាយតក់ក្រហល់តប់ប្រមល់ខ្វក់ខ្វល់ក្រៀមក្រំចិត្ត អ្នកដែលមានហើយក៏មិនបេះល្មម ខំស្វែងរកមកបាន នៅត្រូវកង្វល់ខ្វាយអន្តរាយទៅវិញ; សង្គ្រាមក្នុងកាមភពនេះ ទាំងដែលមានមកហើយ ទាំងដែលកំពុងមាន ហើយនឹងមានតទៅ រមែងកើតព្រោះកាមទាំងអស់ ដូចនឹងឃើញបានថា ការតស៊ូដើម្បីដណ្ដើមស្រី របស់ប្រុសកំឡោះ ដែលជាហេតុដល់ស្លាប់ឬត្រូវចុះទោសនោះ ក៏ព្រោះកាមជាហេតុ ការតស៊ូរវាងប្រទេសចំពោះប្រទេស ដើម្បីសេចក្ដីចំរើនរបស់ចំណែកខ្លួន ឬដើម្បីដណ្ដើមសម្បត្តិវត្ថុ ឫទ្ធិអំណាច ក៏មានកាមជាហេតុ ៗ ឬមិនដូច្នោះខំប្រឹងប្រែងស្វែងរកទ្រព្យសម្បត្តិបានមកហើយ នៅមិនទាន់បានចាយវាយ ប្រើប្រាស់ឲ្យសុខចិត្ត ទ្រព្យនោះក៏វិនាសទៅ ដោយចោរភ័យ អគ្គិភ័យខ្លះ ល្មមនឹងរកសេចក្ដីសុខបាន ក៏ស្លាប់ចោលខ្លះ ៗ

ទេវតាទាំងឡាយ ដែលមានក្នុងច្បាប់ផ្សេងៗ ពណ៌នាទុក ក៏គ្រប់គ្រងសេចក្ដីសុខ ទៅបានត្រឹមធ្វើសេចក្ដីល្អទុក កាលអស់បុណ្យក៏ទៅកើតក្នុងទីដទៃតទៅទៀត ខ្លះដែលធ្វើទុកទាំងល្អទាំងអាក្រក់ ផលសេចក្ដីល្អនាំឲ្យកើតជាទេវតាមុន កាលអស់សេចក្ដីល្អហើយ ផល

របស់សេចក្ដីត្រេក ក៏ស្ទួននាំទៅកើតជានរកក៏មាន ៗ កាមធ្វើឲ្យមនុស្សក្រោបខ្លួនក្រោប ស្លាប់ ធ្វើឲ្យសុខមួយដងមួយយាម ហើយធ្វើឲ្យទុក្ខច្រើនព្រោះខ្លាចក្រែង របស់ដែលខ្លួនស្រឡាញ់នោះ ៗ ប្រែប្រួលវិនាសបុក្ខាស់ដៃ ទៅជារបស់មនុស្សដទៃ ៗ កាមធ្វើឲ្យមនុស្សវង្វេងវង្វេនគន្លងប្រឡំ ឲ្យតណ្ហាឈ្លានីសត្វ ទឹងខសំខាន់បំផុតគឺធ្វើឲ្យមនុស្សឃើញសុខក្នុងទុក្ខធ្វើឲ្យមនុស្សវិលស្លាប់កើត ក្រខ្លះមានខ្លះធ្លាក់នរកខ្លះឡើងឋានសួគ៌ខ្លះ ជាតិរច្ឆានខ្លះ ជាមនុស្សខ្លះ មិនរួចទៅចាកសង្សារវដ្តបាន

កាលឋានៈ ឬ សភាពតាមពិតរបស់ឋានសួគ៌ កាមសុខទាំងរបស់មនុស្សនិងទេវតា មិនមានសេចក្ដីគង់វង់គត់មត់អ្វី មានហើយក៏ដូចជាគ្មាន មានហើយក៏យកទុកជារបស់ខ្លួនមិនបាន ត្រូវស្លាប់ឬចុតិ ទាំងសម្បត្តិ គឺរូប សំឡេងជាដើម ទុកជារបស់មនុស្សដទៃតទៅ ដូចនេះកាមសុខជាសុខទាក់ទងដោយអាមិស គឺចំពាក់ដោយគ្រឿងល្បួងលោម មានទុក្ខនៅប្រឡំបល់ មិនមែនជាសុខពិតឡើយ ។

" សុខនាលោក សោកនៅលាយ មិនសុខសប់
សុខក្នុងភព ផង់ក្នុងគក់ វក់កាមា ៗ
កាមនេះឯង តែងហុំកហាក់ ទឹងហាំហា
ហើយហិនហោច ទឹងខ្លោចផ្សា មកពេបពេះ
ព្រោះធម្មតា ការកើតឡើង តែងប៉ុននៅ

ទប់មិនទឹង  តាំងមិននៅ  ត្រូវវិនាស
គ្រប់និករ  គ្រប់និកាយ  គ្រប់ជាតិសាសន៍
បានសុខខ្លះ  ប៉ះទុក្ខគ្នា  ធម្មតាធម៌ ។
សុខកើតឡើង  ប៉ើនទុក្ខទៅ  មួយរំពេច
លុះទុក្ខលេច  គេចឃើញសុខ  មកលោមល
សុខបាត់ក្លាម  ចេញទុក្ខក្លែត  មកដំណ
សឹងវិករ  សែនរឹមរាម  ក្នុងរាលវដ្ដ ”

កាមតោ ជាយតេ សោកោ  កាមតោ ជាយតេ ភយំ
កាមតោ វិប្បមុត្តស្ស  នត្ថិ សោកោ កុតោ ភយំ

“ សេចក្ដីសោក  យោកយោបំ  យំតក់ស្លុត
ភ័យរន្ធត់  រមែងកើត  ពីចំណង់
សោករលត់  បាត់ពីអ្នក  ដែលអស់ចង់
ភ័យភិតល្ងន់  នឹងមានមក  ពីណាបាន?” ។

ការបូជាយញ្ញ  របស់មនុស្សសម័យបុរាណ  ដើម្បីឲ្យទេវតាចូលចិត្តក្ដី  ដើម្បីឲ្យកើតជាទេវតាក្ដី សុទ្ធតែមានបំណងប៉ងចំពោះកាមសុខ មានរូប សំឡេងជាដើម ព្រោះហេតុនោះ លោកជដិលឧរុវេលកស្សប ដែលពីដើមនិយមបូជាយញ្ញសំដៅទៅឋានសួគ៌ លុះមកជួបព្រះពុទ្ធជាម្ចាស់ បានស្ដាប់ធម៌ទេសនាកើតជ្រះថ្លានឹងព្រះសាស្ដា ក៏លះ

ហោលលទ្ធិនោះ ទើបប្រកាសផល់ប្រជុំជន មានព្រះបាទពិម្ពិសារជាប្រធានថា "យញ្ញទាំងឡាយ សរសើរកាមមនុស្សស្រីយ៉ាងខ្ពស់ ព្រោះដូច្នោះ លោកឃើញជាមន្ទិលទើបលះហោល មកធ្វើតាមឱវាទរបស់ព្រះពុទ្ធម្ចាស់ ដែលនាំឱ្យរកសេចក្ដីស្ងប់ ដោយការចេញចាកកាម ជាសេចក្ដីសុខដែលហៅថាសន្តិសុខ ។

ដូចពោលមកនេះ ក៏ឃើញបានថា ឋានសួគ៌មិនមែនរបស់ល្អអ្វីណាស់ ព្រោះល្អមិនយឺនយូរ គង់ដំណាលរបស់សាសនាផ្សេងៗ ឯង ក៏នៅមានទេវតា ច្បាំងតាក់កាប់ឥទ្ធាឫស្យាគ្នា ប្រណាំងប្រជែង ដណ្ដើមគ្នាធ្វើជាម្ចាស់ជាធំ ព្រោះហេតុនោះព្រះពុទ្ធសាសនា មិនកាន់ឋានសួគ៌ជាសំខាន់ឬជាគោលបំណង យ៉ាងខ្ពស់បំផុតឡើយ ។

កាលព្រះពុទ្ធម្ចាស់ ត្រាស់រឿងទាននឹងសីល ហើយពណ៌នាអានិសង្សរបស់ទានសីល ដោយលើកឋានសួគ៌ឡើង សំដែងឱ្យរីករាយចិត្ត ហើយទើបពណ៌នាទោសរបស់កាម ដែលឱ្យឃើញថាសូម្បីសុខ ក្នុងឋានសួគ៌ ក៏មិនទៀងទាត់ ដូចពោលមកហើយនេះ ក្នុងលំដាប់តទៅ ព្រះអង្គទើបត្រាស់រឿងនេក្ខម្ម: គឺការចេញចាកកាម ឬអានិសង្សរបស់ការបួស ដែលនឹងអធិប្បាយតទៅនេះ ៖

## ៥-នេក្ខម្មានិសង្ស

សេចក្ដីវិលត្រឡប់ ស្លាប់កើត សោយសុខខ្លះ ទុក្ខខ្លះ នឹងដោយច្រើន

សោយទុក្ខ ព្រោះមនុស្សធ្វើសេចក្ដីអាក្រក់ ហើយមិនធ្វើសេចក្ដីល្អ ផលនៃសេចក្ដីអាក្រក់ ទើបអំណោយឲ្យសេចក្ដីទុក្ខផ្សេងៗ ដូចដែលឃើញរាល់ថ្ងៃនេះ ហៅថា វដ្ដសង្សារ ប្រែថា "ការវិលត្រឡប់ក្នុងវង់មូល" ។

វង់មូលនេះ ជាសភាពសៅហ្មងដោយសេចក្ដីកើតសេចក្ដីចាស់ និងសេចក្ដីស្លាប់ ។ នរណាមិនវិសេសពិស្ដារយ៉ាងណា បើនៅកិលេសតណ្ហា ក៏មិនរួចពីវដ្ដសង្សារទៅបានឡើយ ។

សត្វលោក ទើបនាំគ្នាត្រាច់ស្ទាត់ក្នុងវដ្ដសង្សារ ដែលវិលគ្នា ៣ យ៉ាង គឺកិលេសជាហេតុឲ្យធ្វើកម្ម កម្មជាហេតុឲ្យកើតផលរបស់កម្ម ដែលហៅថាវិបាក វិបាកជាហេតុឲ្យកើតកិលេស ហៅខ្លីៗថា កិលេសវដ្ដ: ១ កម្មវដ្ដ: ១ វិបាកវដ្ដ: តាំង ៣ នេះ ជាប់ទាក់ទងគ្នា វិលចុះវិលឡើងជាដរាប មិនចេះចប់មិនឈប់ឈរ មិនអស់ផុត មិនមានទីបំផុត ព្រោះកាលស្លាប់ហើយ ក៏វិលកើតទឹងចាស់ ឈឺស្លាប់តទៅទៀត កើតហើយក៏រស់ជាបាវព្រាវ ទំនុកដំរបស់រាងកាយ ដោយការរកអាហារមកចិញ្ចឹម រកគ្រឿងស្លៀកពាក់ ទីជាក់អាស្រ័យ រហូតដល់ថ្នាំកែរោគ បំណាច់បំណងបានមក ទំនុកបំរុងរាងកាយនេះតាំងតែពីកើតរហូតដល់ស្លាប់ទៅ ទឹងត្រូវក្ដៅក្រហាយ កាលមាននរណាមកជេរស្ដី តិះដៀលរាងកាយនេះ ដែលសន្មតិគ្នាហៅថា អ្នកនេះ នាងនេះ អញ ឯងជាដើម ។

កណ្ដាលចំហាយកំដៅថ្ងៃយ៉ាងខ្លាំង ឬកណ្ដាលភ្លៀងផ្គររន្ទះ ក៏ត្រូវទ្រាំធ្វើការ ដើម្បីចិញ្ចឹមរាងកាយនេះទុក ការងារធ្ងន់សូម្បីជាបាវព្រាវខ្ញុំកំដរគេ ក៏ព្រមអត់ទ្រាំ ដើម្បីសេចក្ដីឆ្អែតពោះ រស់ជីវិតខ្លួននិងប្រពន្ធកូនជាដើម នេះសំដែងឲ្យឃើញថា មនុស្សសត្វទាំងឡាយ នាំគ្នាជាទាសៈយ៉ាងទាបបំផុតរបស់រាងកាយនេះ តែរាងកាយក៏នៅតែមិនគង់វង់ ទៀងទាត់ឋិតថេរដូចសេចក្ដីប្រាថ្នាឡើយ កាលដល់ការៈ ទីបំផុតក៏រលត់រលាយចោលសេចក្ដីសោកស្ដាយ អាឡោះអាល័យនឹងសង្វេគទុកដល់ម្ចាស់រាងកាយដទៃ ៗ ដែលមានជីវិតរស់នៅ ។ រាងកាយនេះមិនគង់វង់ តែងវិលវិញរុះទ្រុឌទ្រោមប្រែក្លាយ ពាយរលត់រលើងទៅ ហើយត្រូវផ្លាស់កំណើតកើតជាថ្មីទៀត ។ ជាតិខ្លះកើតជាមនុស្ស ជាតិខ្លះកើតជាសត្វតិរច្ឆាន ជាតិខ្លះបានកើតជាសេដ្ឋី ជាតិខ្លះ កាឡកណ្ណី កើតជាអ្នកសូមទានគ្មានទីពឹង ព្រោះដូច្នោះ សេចក្ដីសុខក្នុងវដ្ដសង្សារដែលរកបានក្រជាងសេចក្ដីទុក្ខ ។

មនុស្សបំពួកខ្លះ ដែលគិតឃើញដូចនេះ ដូចព្រះពុទ្ធម្ចាស់គ្រានៅសោយកាមសុខសម្បត្តិ ឬ យសកុលបុត្ត មានមនុស្សបំរើដោយកាមគុណ ដ៏គួរសប្បាយក្រៃកសប្បាយចិត្ត មាននារីសុទ្ធតែក្រមុំច្រៀងរាំបំពេរដោយតូរ្យតន្ត្រីឲ្យរីករាយ ប្រាសាទនឹងទ្រព្យសម្បត្តិសម្បូណ៌ឥតខ្វះ តែលោកក៏មានវេលាមួយ ដែលនឹកឃើញរបស់ទាំង

នេះដូចព្រៃខ្មោច ឃើញនារីទាំងឡាយដែលដេកលក់នៅដេរដាស ដូចសាកសព ។

សេចក្ដីវិលត្រឡប់ទាំងនេះ ប្រៀបដូចសេចក្ដីងងឹត បើរកផ្លូវឲ្យកើតភ្លឺស្វាងបាន ក៏ប៉ុន្តែគ្មាននឹងរកឃើញផ្លូវ ធ្វើឲ្យរួចទុក្ខបាន ។ លោកទើបពោលថា វដ្តទាំងឡាយរមែងមានជាគូគ្នា ឬ ផ្ទុយគ្នា គឺមានងងឹត មានភ្លឺ មានត្រជាក់ មានក្ដៅ កាលមានទុក្ខ ក៏ត្រូវមានសុខ មានកើតចាស់ ឈឺស្លាប់ ក៏ត្រូវមានមិនកើត មិនចាស់ មិនឈឺ មិនស្លាប់ ។

ព្រះពុទ្ធទ្រង់ត្រិះដូចនេះ ទើបលះសម្បត្តិទាំងពួងចេញបួស កាលជាអ្នកចេញចាកកាមទាំងកាយនិងចិត្តបានហើយ អប់រំចិត្តនិងបញ្ញាឲ្យចំរើនពេញទី ក៏មានលុះដល់នូវសេចក្ដីជាអ្នក មិនវិលត្រឡប់ស្លាប់កើតទៀតតទៅ ព្រោះមិនមានកិលេសដែលជាហេតុឲ្យធ្វើកម្ម ឬសោយផលរបស់កម្ម ជាវដ្ដវិល ដូចសំដែងមកហើយ ។

ការចេញបួស, បួសប្រែថា វៀរខ្លួនទៅ គឺវៀរចាកសេចក្ដីអាក្រក់ផ្លូវ កាយ វាចា ចិត្ត និងមិនពាក់ព័ន្ធនឹងកាមគុណទៀត, ជាឧបាយដែលនឹងស្ងប់បានងាយជាងការគ្រប់គ្រងផ្ទះ ព្រោះការនៅគ្រប់គ្រងផ្ទះ មានការចំពាក់ពាក់ទិនដោយចំណងផ្សេងៗ មានកូនប្រពន្ធទ្រព្យសម្បត្តិជាដើម ។ កាលជាអ្នកស្ងាត់ចាកកាមទាំងកាយចិត្ត ដោយការហ្វឹកហាត់

ចិត្ត អប់រំចិត្តឲ្យកើតប្រាជ្ញា តាមច្បាប់ដែលព្រះពុទ្ធជាម្ចាស់ផ្ទប់ប្រទ ទីនបញ្ញត្តទុកហើយ រមែងជាហេតុឲ្យត្រាស់ដឹងអរិយសច្ច ៤ ប្រការ ដែលជាធម៌ខ្ពស់បំផុតផ្លូវពុទ្ធសាសនា ជាហេតុឲ្យរួចចាកវដ្តសង្សារ មិនត្រូវកើត ចាស់ ឈឺ ស្លាប់ តទៅទៀតឡើយ ។

ការសំដែងថ្ងៃនអំពី អនុបុព្វិកថា ៥ ប្រការដោយសង្ខេបបែបៈ ចប់សេចក្តីតែប៉ុណ្ណះ ។

— ឃ្វិ —

រោងពុម្ព អាស៊ី លេខ ០៩៩
វិថីព្រៃនគរ ភ្នំពេញ